**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុនស្មាតស៊ើតស៍ ហ្គាមេនមេនូហ្វេគធើរីង( ខេមបូឌា) ខូអិលធីឌី**

# កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល៥៣ថ្ងៃ

ថ្ងៃច័ន្ទ ៥ កើតខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៤: 00នាទីល្ងាច មានកិច្ចប្រជុំមួយនៅរោងចក្រស្មាតស៊ើតស៍ ហ្គាមេនមេនូហ្វេគធើរីង( ខេមបូឌា ) ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិ ស្រង់ ឃុំស្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានលោក ZHANG LIANG ជានាយកក្រុមហ៊ុនបានបើកកិច្ចប្រជុំមួយជាមួយ បងប្អូនដែលជាប្រតិភូបុគ្គលិកចំនួន ១៩នាក់ដែលតំណាងអោយកម្មករ កម្មកការិនី សរុប ១២១៥នាក់។

ជាកិច្ចចាប់ផ្តើមលោក ZHANG LIANG ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់ប្រតិភូបុគ្គលិក ទាំងអស់ដែលបានចូលរួម និងបានបើកកិច្ចពីភាក្សាអំពីការព្យួកិច្ចសន្យាការងាររបស់កម្មករ និយោជិកចំនួន៤០២នាក់ (ស្រី៣៦២នាក់)ក្នុងចំណោមក្មករ និយោជិកសរុប ១២១៥នាក់ (ស្រី១០៤៨នាក់) សម្រាប់រយៈពេល៥៣ថ្ងៃ ដោយចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី២៣ ខែ តុលា ឆ្នាំ២០២៣ដោយស្ថានភាពបញ្ជាបញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមកភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗ៣០ដុល្លារក្នុង១ខែក្នុងនោះ ៖

- ចាប់ពីថ្ងៃទី ០១ ដល់ ៣០ ខែ កញ្ញា ឆ្នាំ២០២៣ ក្រុមហ៊ុនផ្តល់ជូន ៣០ដុល្លារ
- ចាប់ពីថ្ងៃទី ០១ ដល់ ២៣ ខែ តុលា ឆ្នាំ២០២៣ ក្រុមហ៊ុនផ្តល់ជូន ៣០ដុល្លារ

ប្រាក់ឧបត្ថមនេះ ក្រុមហ៊ុននិងបើកជូនកម្មករនៅរៀងរាល់ថ្ងៃទី ១០ នៃខែនីមួយៗ។

ដើម្បីជាភស្តុតាងលើលិខិតស្នើរសុំព្យួរកិច្ចសន្យាការងាររយៈពេល៥៣ថ្ងៃ ដែលចុះ ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០២៣ យើងខ្ញុំទាំងអស់គ្នា ជាប្រតិភូពេញសិទ្ធ ទាំងអស់សូមផ្តិតមេដៃ ដូចខាងក្រោមនេះ

*កំពង់ស្ពឺ.ថ្ងៃទី២១ ខែសីហា ឆ្នាំ ២០២៣*

*ប្រតិភូបុគ្គលិកប្រចាំរោងចក្រ*

*តំណាងក្រុមហ៊ុន*

វី សីហា　　ណើរ សារ៉ាត់　　ឯម ធារ៉ា

*លោក* WANG QIAO

| | | | |
|---|---|---|---|
| ជឹម ស្រីណាក់ | សៀង សុជាតិ | ថន សំអាត | ម៉ែន មិនា |
| លាង ចរិយា | ភួង សុគន្ធ | ស៊ុំ ស្រីម៉ៅ | សាន់ គន្ធា |
| សាម សុខលី | អឿន សារិត | ឈឹម សុខហួ | ឡុង ស្រីពៅ |
| អ៊ួន ចាន់ធី | លន់ វីណា | ហែល សៅលី | ដើង សារី |